# ច្បាប់សិទ្ធិពលរដ្ឋមាត្រា VI (Title VI)
# សេចក្ដីជូនដំណឹងដល់សាធារណៈជន

អាជ្ញាធរគមនាគមន៍តំបន់ឡូវែល សូមជូនដំណឹងដល់សាធារណៈជននូវគោលនយោបាយរបស់ខ្លួនក្នុងការធានាឲ្យបាននូវការប្រតិបត្តិខ្ជាប់ខ្ជួនទៅនឹងមាត្រា VI នៃច្បាប់សិទ្ធិពលរដ្ឋឆ្នាំ ១៩៦៤, ច្បាប់ស្ដារឡើងវិញនូវសិទ្ធិពលរដ្ឋឆ្នាំ ១៩៨៧ និង ច្បាប់ពាក់ព័ន្ធផ្សេងៗទៀត។ មាត្រា VI និង ច្បាប់ពាក់ព័ន្ធផ្សេងៗទៀតដែលហាមឃាត់ការប្រកាន់ពូជសាន៍ក្នុងកម្មវិធីនានាដែលផ្ដល់ថវិការដោយរដ្ឋាភិបាលសហព័ន្ធដាក់កំហិតថា គ្មានជនណាម្នាក់នៅសហរដ្ឋអាមេរិកត្រូវបានបដិសេធមិនឲ្យចូលរួម, មិនឲ្យទទួលអត្ថប្រយោជន៍ ឬ ត្រូវបានប្រកាន់ពូជសាសន៍ក្រោមក្មវិធី ឬ សកម្មភាពណាមួយដែលផ្ដល់ថវិការដោយរដ្ឋាភិបាលសហព័ន្ធដោយសាជាតិសាន៍ ពណ៌សម្បុរ ជាតិកំណើត, ភេទ, អាយុ ឬ ពិការភាពឡើយ។

ជនណាម្នាក់ដែលជឿថាខ្លួនមានទុក្ខដោយសាការប្រកាន់ពូជសាន៍ទាក់ទងនឹងកម្មវិធីនានារបស់អាជ្ញាធរគមនាគមន៍តំបន់ឡូវែល (LRTA) មានសិទ្ធិដាក់ពាក្យបណ្ដឹងជាផ្លូវការមកកាន់អាជ្ញាធរ LRTA។ ពាក្យបណ្ដឹងនោះ ត្រូវតែធ្វើជាលាយលក្ខអក្សរ ហើយដាក់ជូនមកកាន់អ្នកសម្របសម្រួលផ្នែកមាត្រា VI របស់ LRTA ក្នុងរយះពេល ១៨០ ថ្ងៃ ចាប់ពីថ្ងៃដែលខ្លួនជឿថាមានការប្រកាន់ពូជសាន៍នោះកើតឡើង។ ពត៌មានបន្ថែមទាក់ទងនឹងបណ្ដឹងរដ្ឋប្បវេណីសូមទាក់ទងអ្នកសម្របសម្រួលផ្នែកមាត្រាច្បាប់ (Title VI) តាមអាស័យដ្ឋាន និង ទូរស័ព្ទ ដូចខាងក្រោម:


**អាជ្ញាធរគមនាគមន៍តំបន់ឡូវែល**

**(Lowell Regional Transit Authority)**
**145 Thorndike Street**
**Lowell, MA 01852**
**(៩៧៨) ៤៥៩-០១៦៤**